# បច្ចុប្បន្នភាពជំងឺគ្រុនឈាម

កាលបរិច្ឆេទរបាយការណ៍៖ ៩ មករាឆ្នាំ ២០១៤

**ឆ្នាំ ២០១២–២០១៣**

ដោយ វេ ជួ,   ច   ម៉េងចួ

ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ– បាណកសាស្ត្រ

ពត៌មានថ្មី

ចំនួនស្លាប់គ្រុនឈាមនៅកម្ពុជាក្នុងឆ្នាំ២០១៣ នេះ៥៩នាក់គឺថយចុះ៦៩%បើប្រៀបធៀបរយៈកាល ដូចគ្នាឆ្នាំ២០១២ ដែលមាន១៨៩នាក់ ។ចំនួនករណីឈឺឆ្នាំ២០១៣ មាន១៧៥៣៣ នាក់គឺថយចុះ៥៩ %បើប្រៀបធៀបរយៈពេលរយៈពេលដូចគ្នាឆ្នាំ២០១២ដែលមាន៤២៣៦២នាក់ ។អត្រាឈឺគិតជាចំនួនឈឺក្នុងប្រជាជន១សែននាក់     ឆ្នាំ២០១៣ មាន ១១៩ករណី ។

គួរកត់សំគាល់ថាឆ្នាំនេះខេត្តដែលមានអត្រាឈឺខ្ពស់គឺភាគច្រើនខេត្តដែលនៅជាប់ឬជិតព្រំដែនថៃខេត្តកណ្តាលខេត្តកំពង់ចាមចំណែកខេត្តជាប់ព្រំដែនវៀតណាមមានអត្រាឈឺទារដោយសារអាចពាក់ព័ន្ធសភាពការណ៍តំបន់ដូចជំរាបខាងក្រោម។

កម្ពុជាធ្លាប់មានផ្ទុះគ្រុនឈាម ឆ្នាំ២០០៧ដែលកាលណោះមានឈឺ  ៣៩ ៨៥០ករណីស្លាប់៤០៤នាក់ ហើយការផ្ទុះឆ្នាំ២០១២មានឈឺ៤០ ៩០៩ករណីស្លាប់១៨៩។ តាមការសង្កេតនិន្នាការវិវឌ្ឍន៏ចាប់តាំងពី ឆ្នាំ១៩៩៨  មកការផ្ទុះរាតត្បាតជំងឺគ្រុនឈាមនៅកម្ពុជា មិនដែលពាក់ព័ន្ធនឹង គ្រោះទឹកជំនន់ទេព្រោះថាឆ្នាំដែលមានការផ្ទុះរាតត្បាតគ្រុនឈាមគឺឆ្នាំ ១៩៩៨ ឆ្នាំ២០០៧ ឆ្នាំ២០១២ ក៏ប៉ុន្តែឆ្នាំទាំងនោះគ្មានគ្រោះទឹកជំនន់ទេ។ ប៉ុន្តែឆ្នាំ ២០០០ និងឆ្នាំ ២០១៣ ដែលមានគ្រោះទឹកជំនន់បែរជាគ្មានការផ្ទុះរាតត្បាតទូទាំងប្រទេសនៅកម្ពុជាទៅវិញ។

គិតជាមធ្យមក្នុងជំងឺគ្រុនឈាម១០០០នាក់ តែងស្លាប់១០,២នាក់នៅឆ្នាំ២០០៧ ស្លាប់៤,៤នៅឆ្នាំ២០១២ និងស្លាប់៣,៤នាក់នៅ២០១៣ ក្នុងឈឺ១០០០ករណី។

ការថយចុះអត្រាស្លាប់មធ្យមក្នុងជំងឺ១០០០នាក់នេះដោយមូលហេតុចំនួន២ គួបផ្សំគ្នាគឺ៖

ទី១ –មាតាបិតាយល់ដឹងកាន់តែច្រើន ប្រញាប់បញ្ជូនអ្នកជំងឺមកមន្ទីពេទ្យរដ្ឋទាន់ពេលវេលា។

ទី២–ការកើនឡើងនៃគុណភាពសេវាសុខាភិបាលរដ្ឋ។

ទោះបីយ៉ាងណាក៏យើងនៅតែត្រូវបន្តប្រុងប្រយ័ត្នជានិច្ចដោយទោះគ្មានសញ្ញាផ្ទុះរាតត្បាតទូទាំងប្រទេសយើង ក៏ដោយព្រោះនៅក្នុងតំបន់អាស៊ីអាគ្នេយ៍

មិនទាន់មានប្រទេសណាគេចផុតពីការផ្ទុះរាតត្បាតគ្រុនឈាមទេមិនថាជាប្រទេសមានចំណូលខ្ពស់ ឬទាបទេ ជាពិសេសឆ្នាំ២០១៣ នេះ

ក្នុងខណៈដែលកម្ពុជាគ្មានការផ្ទុះរាតត្បាតស្ថានភាពគ្រុនឈាមប្រទេសជិតខាងយើងមានសភាពការណ៍អាក្រក់ជាងឆ្នាំមុនៗយ៉ាងច្រើនគួរ ឱ្យបារម្មណ៍។ តាមបាងប៉ុស្តិ៍ នៅប្រទេសថៃគិតត្រឹមថ្ងៃទី៦ ខែវិច្ឆិកា មានគ្រុនឈាមជិត១៤ម៉ឺនករណីក្នុងឆ្នាំ២០១៣ ។ចំណែកសិង្ហបុរ ក្នុងឆ្នាំ២០១៣ មានផ្ទុះរាតត្បាតដែលមានគ្រុនឈាមជិត២ម៉ឺននាក់នាំឱ្យអត្រាឈឺក្នុងប្រជាន១សែន នាក់កើនដល់៤២២ករណី ដែលស្មើនឹង៣,៥ដងនៃអត្រាកម្ពុជា (១១៩/១សែន) ក្នុងរយៈកាលដូចគ្នា

ហើយការផ្ទុះរាតត្បាតបានអូសបន្លាយតាំងពីដើមឆ្នាំដល់ចុងឆ្នាំ២០១៣ និងករណីឈឺដើមខែមករាឆ្នាំ២០១៤នៅបន្តកើនឡើងនៅឡើយ (សូមអានក្រាហ្វិកនៅhttp://www.dengue.gov.sg/subject.asp?id=73 ) ។

នៅប្រទេសឡាវឆ្នាំ២០១៣ ករណីឈឺកើនជាង៤ដងលើស ឆ្នាំ២០១២ ហើយអត្រាឈឺស្មើនឹង៦ដងនៃអត្រានៅកម្ពុជា។ផ្ទុយទៅវិញនៅឆ្នាំ ២០១៣ ចំនួនករណីគ្រុនឈាមវៀតណាមថយចុះ ហើយអត្រាឈឺមានទាបជាងអត្រាកម្ពុជា។ **ហេតុនេះយើងឃើញខេត្តកម្ពុជាដែលនៅ ជិត/ជាប់ ប្រទេសវៀតណាមភាគច្រើនមានអត្រាឈឺទាបជាង ខេត្តដែលនៅជិត/ជាប់ប្រទេសថៃ។**

សារបាន អន្តរាគមន៍ នៅកម្ពុជា

អន្តរាគមន៍ជាគន្លឹះឆ្លើយតបនឹងជំងឺគ្រុនឈាម គឺបំបាត់ជំរកមូសខ្លានិងបញ្ជូនអ្នកជំងឺជាពិសេកុមារក្តៅខ្លួនទៅមន្ទីរពេទ្យសារធារណៈឱ្យបានទាន់ពេល ហើយអន្តរាគមន៍ ទាំងនេះត្រូវចាប់ដំបូងបង្អស់ពី **និងគ្រួសារនីមួយៗ និងការចូលរួមរបស់ សហគមន៍នីមួយៗ នោះទេ** ។ អាស្រ័យហេតុនេះ ខ្ញុំសូមអំពាវនាវដោយទទូចសុំ ស្ថាប័ន ពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងបណ្តាញសារព័ត៌មានទាំងអស់ មេត្តាជួយជំរុញចលនាទាំងនេះដើម្បីបញ្ចៀសកុមារ ពីគ្រោះមរណៈដោយការផ្ទុះរាតត្បាតគ្រុនឈាម។កន្លងមកនេះ**៦៩%នៃករណីគ្រុនឈាមសរុប**ជាកុមារអាយុ៥–១៤ឆ្នាំ ដែលភាគច្រើនកំពុងរៀនក្នុងសាលាបឋមសិក្សាហេតុនេះការចូលរួមរបស់ លោកគ្រូ–អ្នកគ្រូនិងសិស្សានុសិស្សជាផ្នែក១ សំខាន់ណាស់ ក្នុងការប្រយុទ្ធនឹងជំងឺគ្រុនឈាមព្រោះថាការយល់ដឹងរបស់សិស្សានុសិស្សអំពីគ្រុនឈាម មានប្រយោជន៍សំរាប់ សាម៉ីខ្លួនផងសំរាប់មាតាបិតានិងប្អូនៗរបស់ពួកគេនៅផ្ទះផង។

សារបាន ទូទៅ:ជំងឺគ្រុនឈាមបង្កដោយ“វីរុសដង់គី” ដែលចម្លងពីមនុស្សម្នាក់ទៅម្នាក់ទៀតដោយមូសខ្លាញីខាំ។តាមឯកសារអង្គការសុខភាពពិភពលោកមកដល់នេះពិភពលោកមិនទាន់មានវ៉ាក់ស

ាំងការពារ ឬ ឱសថប្រឆាំងវីរុសគ្រុនឈាមទេ ហេតុនេះការព្យាបាល ផ្អែកជាសំខាន់លើការព្យាបាលសម្រន់រោគសញ្ញាប៉ុណ្ណោះ ហើយប្រជាជន ២៥០០លាន នាក់កំពុងប្រឈមនឹងការឆ្លងវីរុសគ្រុនឈាមក្នុងនោះ៧០% នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ តាមការក្រាសលទ្ធផលស្រាវជ្រាវថ្មីៗនេះរបស់សាកលវិទ្យាល័យ អុកស្វ័ត និងមូលនិធិវែលខមត្រើសក្នុង១ឆ្នាំៗ មានប្រជាជន៣៩៦នាក់ ក្នុងសកលលោកបានឆ្លងវីរុសគ្រុនឈាមក្នុងនោះមាន៩៦លាននាក់ (១ភាគ៤)មានរោគសញ្ញាដែលតម្រូវឱ្យចូលសំរាកពេទ្យ ហើយមាន ២៩៤លាននាក់ជាអ្នកបានឆ្លងវីរុសគ្រុនឈាម ប៉ុន្តែអ្នកខ្លះ មាន រោគសញ្ញាស្រាលឬគ្មានរោគសញ្ញា។ តាមទិន្នន័យនេះ កាលណាឃើញមាន កុមារ១នាក់ចូលសំរាកពេទ្យ ដោយសាររោគសញ្ញាគ្រុនឈាមនោះ យើងអាចប៉ាន់ស្មានថានៅមជ្ឈដ្ឋានដែលកុមារនេះរស់នៅអាចមានអ្នកដែលឆ្លងវីរុសគ្រុនឈាមប្រហែល៣នាក់ជាអ្នកបានឆ្លងវីរុសគ្រុនឈាមប៉ុន្តែអ្នកខ្លះមានរោគសញ្ញាស្រាលឬគ្មានរោគសញ្ញា ហើយពួកគេ៣នាក់ដែលជាភ្នាក់ផ្ទុកវីរុសដោយមិនដឹងខ្លួនដែលមូសខ្លាញីខាំអាចខាំចិលងទៅ អ្នកដ៏ទៃបានយ៉ាងងាយ។ ហេតុនេះកាលណាឃើញមានករណីគ្រុនឈាមចូលសំរាកពេទ្យកាន់តែច្រើនហានិយភ័យក្នុងការឆ្លងមានកំរិតកាន់តែខ្ពស់ណាស់សំរាប់សហគមន៍ ដែលអ្នកជំងឺទាំងនោះរស់នៅ។ តាមទិន្នន័យអង្គការសុខភាពពិភពលោក សរុបករណីឈឺក្នុង៣តំបន់ គឺអាមេរិក អាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិកខាងលិចកើនកើន ប្រហែល៩០% ក្នុងរយកាលតែ២ឆ្នាំ គឺឆ្នាំ២០០៨–២០១០។ក្នុងរយៈកាលទសវត្សឆ្នាំ២០០០–២០១០ចំនួនករណី គ្រុនឈាមក្នុងតំបន់អាស៊ានកើន១៩% ជាមធ្យមក្នុង១ឆ្នាំៗ ក្នុងនោះកម្ពុជាកើន១០%ក្នុង១ឆ្នាំៗ ក្នុងទសវត្សដូចគ្នា។